# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២៣៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

មាត្រា ១ និងមាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានកែតម្រូវដូចខាងក្រោម :

**មាត្រា ១ថ្មី.-**

បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយហៅកាត់ថាគ.ជ.គ.ម និងជាអក្សរឡាតាំង ហៅកាត់ថា NCDM មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី២ |
| ៤- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | អនុប្រធាន |

| | |
|---|---|
| ៥- រដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៦- រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- រដ្ឋមន្ត្រី ក្រសួងបរិស្ថាន | សមាជិក |
| ១០- រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | សមាជិក |
| ១៤- រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥- រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៦- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧- រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩- រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | សមាជិក |
| ២០- តំណាង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២១- តំណាងប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា | សមាជិក |
| ២២- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

**មាត្រា ២ថ្មី.-**

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចតទៅ :

ក- អង្កេត តាមដាន វាយតំលៃ ប្រមូល វិភាគ គ្រប់គ្រងទិន្នន័យគ្រោះភ័យនៃគ្រោះមហន្តរាយ និងរៀបចំចងក្រងរបាយការណ៍ស្តីពីស្ថានភាពគ្រោះមហន្តរាយ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលដាក់ចេញនូវគោលការណ៍ គោលនយោបាយ សារាចរ សេចក្តីប្រកាស និងវិធានការសំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយ

ខ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការ និងការប្រើប្រាស់ប្រភពធនធាន ដូចជាមូលនិធិ សម្ភារៈប្រេងឥន្ធនៈ មធ្យោបាយប្រើប្រាស់ និងធនធានមនុស្សដើម្បីដំណើរការកិច្ចប្រតិបត្តិការការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសំរាប់ជួយដល់ជនរងគ្រោះដែលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

គ- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធ ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ភូមិ និងអប់រំផ្សព្វផ្សាយការយល់ដឹងសាធារណៈដល់ប្រជាពលរដ្ឋ នៅសហគមន៍អំពីគ្រោះភ័យនៃគ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្ស

ឃ- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសប្បុរសជន ដើម្បីអនុវត្តគោលនយោបាយជាតិ នៃការងារគ្រប់គ្រងគ្រោះមហន្តរាយ មានដូចជាការត្រៀមបង្ការ ការសំរាល ការត្រៀមរៀបចំ ដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

ង- ធ្វើការទំនាក់ទំនង សំរបសំរួលកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមកអំពីស្ថានភាព និងស្ថានការណ៍ គ្រោះមហន្តរាយ សំដៅកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ

ច- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរស្វែងរកជំនួយសំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរាល់ការខូចខាតដោយគ្រោះមហន្តរាយ ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំរាប់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៣. ០៤០៨.៧៣៧

លេខ: ១៨៦ ចល

ជម្រាបជូនចំពោះ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ហត្ថលេខា

សុខ ឆាយ ផាន